**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

សាលក្រមព្រហ្មទណ្ឌលេខ ២៦៧ ជ
ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩
សំណុំរឿងព្រហ្មទណ្ឌលេខ ១២០
ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពត
កាលបរិច្ឆេទបើកសវនាការនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ វេលាព្រឹក
កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ វេលាព្រឹក

### ចៅក្រមជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពត

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

**ដើម្បីជំនុំជម្រះលើជនជាប់ចោទ** ១.ឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ។ ទីកន្លែងកំណើតនៅភូមិទួលគោក សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និងទីលំនៅបច្ចុប្បន្ន [redacted] ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ [redacted] ,ម្តាយឈ្មោះ [redacted] នៅលីវ "ទីតិជន" ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន "ក្នុងឃុំ" ។

២.ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររត់តាក់ស៊ី ។ ទីកន្លែងកំណើតភូមិស្វាយ ឃុំបឹងសាលាខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត និងទីលំនៅបច្ចុប្បន្ន [redacted] ព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ,ម្តាយឈ្មោះ [redacted] ,ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣នាក់ "ទីតិជន"។ ប្រវត្តនៃការផ្តន្ទាទោសដោយតុលាការ គ្មាន "ក្នុងឃុំ" ។

ជាប់ចោទពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទា ទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៥៥ ព្រទ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត ។

ដោយមានលោកស្រី [redacted] វណ្ណារី ជាមេធាវីការពារសិទ្ធិ ឱ្យជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សំណាង ។

**អង្គហេតុកើតមានឡើងដូចតទៅ**

តាមអង្គហេតុដែលបានចោទប្រកាន់ឃើញថា: កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ០០ នាទី កម្លាំងសមត្ថកិច្ចបាន បង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ០១ ករណីនៅចំណុច ភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ដោយឃាត់ខ្លួនបានជនសង្ស័យ ចំនួន ០២ នាក់ រួមមានឈ្មោះ [redacted]សម្បត្តិ ភេទ ប្រុស អាយុ ២៨ឆ្នាំ និងឈ្មោះ [redacted]សំណាង ភេទ ប្រុស អាយុ ៣៥ឆ្នាំ ដោយបានដកហូត ថ្នាំញៀន ចំនួន ០៣កញ្ចប់ ទម្ងន់ ១០៥,៨៨ក្រាម ជញ្ជីងថ្លឹងអេឡិចត្រូនិចចំនួន ០១គ្រឿង រថយន្តសាំងយ៉ុង ០១គ្រឿង និងថង់ប្លាស្ទិចមួយចំនួន ។ បន្ទាប់មកសមត្ថកិច្ចបានបញ្ជូនជនសង្ស័យទាំងពីរនាក់ និង វត្ថុតាងមកអយ្យការដើម្បីចាត់ការតាមច្បាប់ ។

**នាពេលសវនាការ**

**ក្រោយពីបាន:**

- ស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សម្បត្តិ និងឈ្មោះ[redacted] សំណាង
- ស្ដាប់អំណានចម្លើយរបស់សាក្សីជាសមត្ថកិច្ចឈ្មោះ [redacted]បូរិន
- ស្ដាប់ក្រឡាបញ្ជីអានរបាយការណ៍ ឯកសារ និងកំណត់ហេតុផ្សេងៗទៀត
- ស្ដាប់តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ
- ស្ដាប់ជនជាប់ចោទឈ្មោះ[redacted]សម្បត្តិ និងឈ្មោះ [redacted] សំណាង ធ្វើការកត់សម្គាល់ខ្លីៗបន្ថែម

**ក្រោយពីបានពិនិត្យភស្ដុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

<u>**សំអាងហេតុ**</u>

**យល់ឃើញថា:**

១. កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ០០នាទី កម្លាំងសមត្ថកិច្ចបានបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ០១ករណី នៅចំណុចភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ដោយឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ រួមមានឈ្មោះ [redacted] សម្បត្តិ ភេទ ប្រុស អាយុ ២៨ឆ្នាំ និងឈ្មោះ [redacted]សំណាង ភេទ ប្រុស អាយុ ៣៥ឆ្នាំ ដោយបានដកហូតថ្នាំញៀន ចំនួន ០៣កញ្ចប់ ទម្ងន់ ១០៥,៨៨ ក្រាម ជញ្ជីងថ្លឹងអេឡិចត្រូនិចចំនួន ០១គ្រឿង រថយន្តសាំងយ៉ុង ០១គ្រឿង និងថង់ប្លាស្ទិចមួយចំនួន ។ បន្ទាប់មកសមត្ថកិច្ចបានបញ្ជូនជនសង្ស័យទាំងពីរនាក់ និងវត្ថុតាងមកអយ្យការដើម្បីចាត់ការតាមច្បាប់ ។

២.ចម្លើយរបស់ឈ្មោះ [redacted]សម្បត្តិ នៅមុខចៅក្រមស៊ើបសួរបានឆ្លើយថា នៅថ្ងៃកើតហេតុមិនចាំទេ ខ្លួនបានយកថ្នាំញៀនពីភ្នំពេញហើយបានទៅកំពង់សោមលក់ថ្នាំញៀននៅម្ដុំអូត្រេសបាន៣០ម៉ឺនរៀល ហើយបានជិះ ឡានជាមួយ ឈ្មោះ សំណាង ដល់ជើងភ្នំបូកគោក ពេលរសៀល ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្ដង ។ នៅពេល សមត្ថកិច្ចឃាត់ខ្លួនបានដកហូតបាន ទូរស័ព្ទ Oppo មួយគ្រឿង Samsung មួយគ្រឿង និង Iphone មួយគ្រឿង ថ្នាំញៀនទម្ងន់ ១០០ ក្រាមជាង ចំណែកឈ្មោះ [redacted]សំណាង សមត្ថកិច្ចដកហូតឡាន សាំយ៉ុង មួយគ្រឿង ទូរស័ព្ទ ពីរគ្រឿង និងកាបូបលុយមួយ ។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀន បានរយៈពេល ៥ឆ្នាំហើយ ប្រើជាមួយក្មេងៗ នៅស្ទឹងកែវ ហើយថ្មីៗនេះខ្លួនប្រើប្រាស់ ថ្នាំញៀនជាមួយឈ្មោះ សំណាង ។ ខ្លួនជួញដូរថ្នាំញៀនតាំងពីឆ្នាំ២០១៤ ប៉ុន្តែខ្លួនឈប់ម្ដងហើយ រួចដើមឆ្នាំ២០១៩ ក៏ចាប់ផ្ដើមជួញដូរថ្នាំញៀនធំតែម្ដង ។ ពេលចាប់ផ្ដើមដំបូងខ្លួនជួញ ថ្នាំញៀនតែម្នាក់ឯង

Scanned with CamScanner

ទេដោយសារខ្លួនជំពាក់លុយធនាគារច្រើនពេក ហើយបានជួញថ្នាំញៀនជាមួយឈ្មោះ សំណាង នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ដើម្បីរកលុយ បង់ធនាគារដូចគ្នា ។ រាល់លើកខ្លួនយកថ្នាំញៀនពីភ្នំពេញម្តុំផ្សារ សិនជូរី ហើយយកមកលក់ឱ្យគេនៅកំពង់សោម និង កំពត ដោយប្រើប្រាស់ឡានរបស់ឈ្មោះ សំណាង រហូត ។ ខ្លួនលក់ថ្នាំញៀនមួយខែបានតែពីរដើងទេ ហើយមួយដើង ចំណេញបានប្រហែល ៥០០ដុល្លា ។ ខ្លួននិងឈ្មោះ សំណាង យកលុយចំណេញដើម្បីបង់ធនាគារទាំងពីរនាក់ ។ ខ្លួនទើបតែជួញថ្នាំញៀនជាមួយឈ្មោះ សំណាង បានតែ បីដងទេ ឬកទាំងពេលសមត្ថកិច្ចចាប់ខ្លួននេះ ។ ខ្លួននិងឈ្មោះ សំណាង ប្រើប្រាស់ឡានគាត់ដើម្បីដឹកខ្លួនទៅមកក្នុង ការជួញដូរថ្នាំញៀន ។

ចម្លើយរបស់ឈ្មោះ [redacted] សំណាង នៅមុខចៅក្រមស៊ើបសួរបានឆ្លើយថានៅថ្ងៃកើតហេតុខ្លួនមិនចាំទេ ម៉ោង ១ជាងយប់ ខ្លួនចេញមកពីភ្នំពេញជាមួយឈ្មោះ [redacted] សម្បត្តិ មកដល់ជើងភ្នំបូកគោកម៉ោងប្រហែល ៣រសៀលថ្ងៃស្អែក ព្រោះខ្លួនដេកតាមផ្លូវ ពេលមកដល់ខ្លួនបានឈប់ទិញទឹកហូប និងចុះបត់ជើងនៅផ្លូវឡើងបូកគោកស្រាប់តែមានសមត្ថកិច្ចចូលមកចាប់ខ្លួន និងឈ្មោះ សម្បត្តិតែម្តង ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួន បានដកហូត ទូរស័ព្ទ Iphone6 មួយគ្រឿង និង Huawei មួយគ្រឿង និងកាបូបលុយមានលុយ ២០ ដុល្លា និងលុយខ្មែរ ៤ម៉ឺនរៀល ព្រមទាំងឡានម៉ាកសាំងយ៉ុង មួយគ្រឿងចំណែកឈ្មោះ សម្បត្តិខ្លួនឃើញសមត្ថកិច្ចដកហូតគ្រឿងញៀន ០១កញ្ចប់ធំ និង ០២កញ្ចប់តូច ។ ខ្លួនស្គាល់ឈ្មោះ សម្បត្តិ ប្រហែល ពីរឆ្នាំហើយ ។ នៅអំឡុងខែមករា ឆ្នាំ២០១៩ ខ្លួនបានដឹងថាឈ្មោះ សម្បត្តិលក់ថ្នាំញៀនព្រោះឈ្មោះ សម្បត្តិ បានឱ្យខ្លួនដឹកគាត់ពីភ្នំពេញមកកំពត ហើយបានទៅយកថ្នាំញៀននៅគល់ស្ពានផ្សារដីហុយដោយជិះឡានតែពីរនាក់គាត់ទេហើយមកដល់កំពតឈ្មោះ សម្បត្តិ បានចូលទៅដេកនៅផ្ទះសំណាក់ស៊ុំភមង្គល ប៉ុន្តែមិនដឹងថាឈ្មោះ សម្បត្តិ យកថ្នាំញៀនលក់ឱ្យអ្នកណាទេ ។ ក្រោយពីដឹងថាឈ្មោះ សម្បត្តិ ជួលឡានខ្លួនជិះយកគ្រឿងញៀនមកលក់នៅកំពតហើយ ខ្លួនបានស៊ីឈ្នួលដឹកឈ្មោះ សម្បត្តិមកកំពត ៤ដងទៀត ប៉ុន្តែគាត់មិនដែលជួលអោយលុយខ្លួនទេ ឱ្យតែប្រពន្ធកូនខ្លួនម្តងម្កាល ៤ម៉ឺន ទៅ ១០ម៉ឺន ប្រហែល ០៣ទៅ០៤ដងដែរ ហើយបានជួយបង់លុយធនាគារឱ្យខ្លួនចំនួន ៥០០ដុល្លា បានមួយខែដែរ ។ រាល់ដងឈ្មោះ សម្បត្តិ ឱ្យខ្លួនជូនគាត់ទៅលើបូកគោយក ថ្នាំញៀនឱ្យគេរហូត នៅពេលប្រគល់ថ្នាំឱ្យគេហើយ និងទទួលលុយហើយខ្លួនចុះមកវិញមក ខ្លួនមិនបានដឹងច្រើនទេ ដឹងតែបើកឡានជូនគេតែប៉ុណ្ណោះ ។

៣. ជនជាប់ចោទឈ្មោះ [redacted] សំណាង ទោះបីខ្លួនមិនមានថ្នាំញៀនយកទៅជួញដូរក៏ដោយ ក៏ជននេះបានដឹងយ៉ាងច្បាស់ថា ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានជួញដូរថ្នាំញៀន ជាញឹកញាប់ ហើយខ្លួនបានផលចំនេញដោយយករថយន្តរបស់ខ្លួន ដឹកជញ្ជូនថ្នាំញៀនរបស់ឈ្មោះ [redacted] សម្បត្តិ ដោយឈ្មោះ [redacted] សម្បត្តិ ជាអ្នកធានារ៉ាប់រងបង់លុយធនាគារអោយ ដើម្បីផ្គត់ផ្គង់ជីវភាព ដូច្នេះអំពើ ប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង នេះគឺជាសហចារី ដែលត្រូវផ្តន្ទាទោសដូចជាចារីដែរ ។

៤. តាមលិខិតលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៧៣៤៨/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លទ្ធផលវិជ្ជមាន [illegible]សំណាកជាគ្រឿងញៀន ប្រភេទក្រាមម៉្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក) ដែលមានកំរិតភាពសុទ្ធ ៧៩,៤៥% នៃទម្ងន់សរុប ស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែង[illegible]ក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

Scanned with CamScanner

៥. តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន របស់ការិយាល័យគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តកំពត និងកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាងចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ ដើម្បីបញ្ជូនសំណាកទៅធ្វើកោសល្យវិច័យ ឃើញថាថ្នាំញៀនប្រភេទក្រាមម៉ៅ្យផ្កាពណ៌សទម្ងន់សរុប ១០៥,៨៨ក្រាម បើគិតបរិមាណភាពសុទ្ធគឺ ១០៥,៨៨ក្រាមX៧៩,៤៥% ចែកនឹង១០០ = ៨៤,១២១៦៦ក្រាម ។

៦. យោងសំអាងហេតុដូចដែលបានលើកឡើងខាងលើនេះ ឃើញថា មានភាពស៊ីចង្វាក់គ្នាទៅនឹងវត្ថុតាងគ្រឿងញៀនដែលដកហូតពីជនជាប់ចោទចំនួន ០៣កញ្ចប់តូច និង០២កញ្ចប់ធំ ទម្ងន់ ១០៥,៨៨ ក្រាម ជញ្ជីងថ្លឹងគ្រឿងញៀន០១គ្រឿង និងថង់ច្រកគ្រឿងញៀនមួយចំនួន មានសារធាតុប្រភេទ មេតំហ្វេតាមីន ស្ថិតក្នុងចំណាត់ថ្នាក់សារធាតុហាមឃាត់ក្នុងតារាងទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាលទ្ធិផលនៃការ ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌បង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សំណាង ពិតជាបានប្រព្រឹត្តអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូចក្នុងអង្គហេតុចោទប្រកាន់ប្រាកដមែន ។

៧. ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សំណាង ជានីតិជនមានស្មារតីយល់ដឹងនូវអំពើដែលខ្លួនបានប្រព្រឹត្ត និង ព្យសនកម្មដែលបានកើតឡើងអំពើនេះបានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម ដែលមានភស្តុតាង និងធាតុ ផ្សំគ្រប់គ្រាន់កំណត់បានជាបទល្មើសជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូចមានក្នុងបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨. មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សំណាង ពីបទ ជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវ សារធាតុញៀន ប្រព្រឹត្តនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩. គប្បីប្រកាសទោសដាក់ពន្ធនាគារដល់ជនជាប់ចោទ ក្នុងកម្រិតលើអតិបរមានៃ ទោសដែលខ្ពស់ជាងគេ ដោយពិចារណាពីសកម្មភាព នៃអំពើល្មើស និងព្យសនកម្មដែលបានកើតឡើងក៏ដូចជាផ្អែកលើស្ថានភាពកាលៈទេសៈផ្សេងៗ ទៀតរបស់ជនជាប់ចោទដែលបង្ហាញពីភាពធ្ងន់ស្រាលនៃបទល្មើស ។

១០. អំពីវត្ថុដែលចាប់យកមានដូចជា គ្រឿងញៀនម៉ាទឹកកកចំនួន ០៣កញ្ចប់តូច និង០២កញ្ចប់ធំ មានទម្ងន់ ១០៥,៨៨ ក្រាម ជញ្ជីងថ្លឹងគ្រឿងញៀន ០១គ្រឿង និងថង់ច្រកគ្រឿងញៀនមួយចំនួន គប្បីសម្រេចរឹបអូស និងបំផ្លាញចោលយោងតាមបញ្ញត្តិមាត្រា ៨៤ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១១. មេធាវីការពារសិទ្ធិអោយជនជាប់ចោទបានស្នើសុំឱ្យចៅក្រមជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តី របស់ខ្លួនដោយសារកូនក្តីខ្លួនបានសារភាពនិងបានដឹងពីកំហុសហើយ ។

១២. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សំណាង ពិនិត្យឯកសារផ្សេងៗពាក់ព័ន្ធក្នុងសំណុំរឿងឃើញថាជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សំណាង ពិតជាបានជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន ហើយចម្លើយសារភាពរបស់ ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សំណាង មានភាពស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍របស់សមត្ថកិច្ច និងលទ្ធផលនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ។ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែលនិងប្តឹងសុំឱ្យតុលាការផ្តន្ទាទោស ជនជាប់ចោទទៅតាមច្បាប់ ។

Scanned with CamScanner

## <u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី</u>

**១.ផ្តន្ទាទោស** ជនជាប់ចោទ៖

១. ឈ្មោះ[redacted] សម្បត្តិ ភេទ ប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ កំណត់រយៈពេលចំនួន ១៣(ដប់បី)ឆ្នាំគិតពីថ្ងៃឃុំខ្លួន

២. ឈ្មោះ[redacted]សំណាង ភេទ ប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ កំណត់រយៈពេលចំនួន ១០(ដប់)ឆ្នាំគិតពីថ្ងៃឃុំខ្លួន

ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២. វត្ថុតាងមាន:

-គ្រឿងញៀនប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន ០៣កញ្ចប់តូច និង ០២កញ្ចប់ធំ ទម្ងន់ ១០៥,៨៨ ក្រាម (ក្នុងកញ្ចប់បិទជិត) ,ជញ្ជីងថ្លឹងគ្រឿងញៀន ០១គ្រឿង និងថង់ច្រកគ្រឿងញៀនមួយចំនួន ត្រូវរឹបអូស និងបំផ្លាញចោល យោងតាមបញ្ញត្តិមាត្រា ៨៤ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

Scanned with CamScanner